**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧៥៦ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.១០....ខែ.មីនា....ឆ្នាំ ២០១៦

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍អំពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករក្នុងរយៈពេល២ខែដើមឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា នៅរយៈពេល២ខែដើមឆ្នាំ២០១៦នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ National Phytosanitary database (NPD/GDA from 07:00/01.01.2016 to 17:00/29.02.2016) ដែលជាតួលេខនៃការនាំចេញតាមរយៈការរៀបចំវេចខ្ចប់គ្រប់ចំនួនរួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យដើម្បីនាំចេញមានដូចខាងក្រោម ៖

១ -ស្ថានភាពនៃការនាំចេញអង្ករ៖

- បរិមាណអង្ករនាំចេញមានចំនួន៩៥.៩៤៥តោន មានការកើនឡើងចំនួន២២.៣៤៨តោន (+៣០,៤%) លើសបរិមាណនាំចេញរយៈពេល២ខែដើមឆ្នាំ២០១៥ ដែលនាំចេញបានតែ៧៣.៥៩៧តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែកុម្ភៈនេះមានដល់ ៥១.៩១២តោនដែលមានកំណើន១៤.២៣៦តោន(+៣៧,៨%)លើសខែកុម្ភៈឆ្នាំមុន (សូមបង្ហាញជូនក្នុងតារាងទី១នៃឧបសម្ព័ន្ធ)

- អង្ករក្រអូបគ្រប់ប្រភេទមានបរិមាណនាំមុខគេដែលមានកំណើនកើនឡើងរហូតដល់៤៦.១៩៩តោន ស្មើនឹង៤៨,១% អង្ករ ស គ្រប់ប្រភេទមានចំនួន ៤៤.១២១តោនស្មើនឹង៤៦% និងអង្ករចំហុយ ៥.៦២៥តោនស្មើនឹង ៥,៩% នៃបរិមាណអង្ករសរុបដែលនាំចេញក្នុងរយៈពេល២ខែដើមឆ្នាំនេះ។ ក្នុងចំណោមអង្ករក្រអូបនោះអង្ករផ្កាម្លិះ (Jasmine rice) និងផ្ការំដួលជាប្រភេទអង្ករដែលបាននាំចេញច្រើនជាងគេមានបរិមាណរហូតដល់២៨,៣០១ស្មើនឹង ២៩,៤% (លំដាប់ទី១) អង្ករក្រអូបចម្រុះ(នាងក្រអូប នាងសយ និងពូជដទៃ)មានបរិមាណ ១២,៩១២ ស្មើនឹង ១៣,៥% (លំដាប់ទី២) អង្ករក្រអូបនាងម្លិះមានបរិមាណ២.៩៩៤ ស្មើនឹង៣.១% (លំដាប់ទី៣) អង្ករត្លីមានបរិមាណ៩៦៨តោន ស្មើនឹង ១% (លំដាប់ទី៤) អង្ករក្រអូបសរីរង្គមានបរិមាណ ៥៩៤តោនស្មើនឹង០.៦% (លំដាប់ទី៥) និងសូមាលីមានបរិមាណ៤៣០តោន ស្មើនឹង០.៤% (លំដាប់ទី៦) (សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ)

-អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៤៤ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (២០.៤៣៦តោន) ប្រទេសបារាំងឈរលំដាប់ទី២ (១២.៤៥៤តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (១០.៧៨៤តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (៦.០០២តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (៤.៦៣៦តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៦ (៤.៥៨៦តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៧ (៣.៥៧៦តោន) ប្រទេសបែលហ្ស៊ិកឈរ លំដាប់ទី៨ (៣,៤៥២តោន) ប្រទេសឆេកឈរលំដាប់ទី៩ (៣,៣៧៩តោន) និងប្រទេសហុងគ្រីឈរលំដាប់ទី១០ (៣,២១៥តោន)

- បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហគមន៍អឺរ៉ុប២៤ប្រទេសមាន បរិមាណសរុប ៦២.២៩៦តោន (៦៤,៩%) ទិសដៅអាស៊ាន៣ប្រទេសមានបរិមាណសរុប ៨.៥៦៥តោន (៨,៩%)

និងទិសដៅដទៃទៀត១៧ប្រទេសមានបរិមាណសរុប២៥.០៨៤តោន (២៦,១%) (សូមបង្ហាញជូនក្នុងតារាងទី៣នៃឧបសម្ព័ន្ធ)

-ការនាំចេញអង្ករមាន ៥៩ក្រុមហ៊ុន (កើនឡើងចំនួន១១ក្រុមហ៊ុនធៀបនឹងខែមករា) ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេ ដោយៈ (ទី១).ក្រុមហ៊ុន Nicoline មានចំនួន១២.៤៨១តោន (ទី២).ក្រុមហ៊ុន Khmer Food មានចំនួន១១.៧៣៨តោន (ទី៣).ក្រុមហ៊ុន Amru Rice មានចំនួន៨.២៦៩តោន (ទី៤).ក្រុមហ៊ុន BAITANG មានចំនួន៥.១៦១តោន (ទី៥).ក្រុមហ៊ុន City Rice import Export មានចំនួន៥.០២៣តោន (ទី៦) ក្រុមហ៊ុន T.O.T មានចំនួន៤.៧៦៧តោន (ទី៧).ក្រុមហ៊ុន International Rice Trading មានចំនួន៤.៧០៦តោន (ទី៨).ក្រុមហ៊ុន Cristal Rice ចំនួន៤.៧០១តោន (ទី៩).Golden Rice ចំនួន៤.៤៨៥តោន (ទី១០).ក្រុមហ៊ុន Signatures Of Asia មានចំនួន៣.៤១០តោន (សូមបង្ហាញជូនក្នុងតារាងទី៤នៃឧបសម្ព័ន្ធ)។ បរិមាណអង្ករដែលនាំចេញដោយក្រុមហ៊ុនធំៗទាំង១០មានចំនួនសរុប រហូត ៦៤.៧៤១ តោនស្មើនឹង៦៧,៥% នៅពេលដែលក្រុមហ៊ុន៤៩ដទៃទៀតនាំចេញបានតែ ៣១.២០៤ តោនស្មើនឹង ៣២,៥% ប៉ុណ្ណោះ។

២-សន្និដ្ឋានៈ

បរិមាណអង្ករនាំចេញសរុបក្នុងរយៈពេល២ខែដើមឆ្នាំ២០១៦ មានចំនួន ៩៥.៩៤៥តោន ដែលបរិមាណនេះ មានកំណើនប្រមាណ៣០,៤% ធៀបនឹងបរិមាណនាំចេញរយៈពេល២ខែដើមឆ្នាំ២០១៥។

លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ ដែលជាសេនាធិការរបស់ក្រុមការងារទី៩ បន្តពង្រីកវិសាលភាព ប្រសិទ្ធភាពដើម្បីបំពេញតួនាទីក្នុងការបង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធ (សមត្ថកិច្ចដែលពាក់ព័ន្ធនឹងបែបបទនាំចេញអង្ករ ក្រុមហ៊ុននាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករ ក្រុមហ៊ុនដឹកជញ្ជូន។ ល ។ ដែលកំពុងមានសកម្មភាពនាំចេញអង្ករ) ក្នុងការរៀបចំទុកដាក់ស្រូវ អង្ករមុននាំចេញប្រកបដោយគុណភាព និងបំពេញបែបបទឲ្យបានសមស្របដោយអនុលោមតាមល័ក្ខខ័ណ្ឌតម្រូវរបស់ប្រទេសនាំចូល និងរាល់កិច្ចព្រមព្រៀងជាធរមានរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយប្រទេសនាំចូល។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត វ៉េង សាខុន**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

# **ឧបសម្ព័ន្ធ:** របាយការណ៍អំពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាប្រចាំខែកុម្ភៈឆ្នាំ២០១៦

**(ANNEX: THE REPORT ON CAMBODIAN RICE EXPORT STATUS IN FABRUARY, 2016)**

(Base on NPD/GDA from 07:00/01.01.2016 to 17:00/29.02.2016 and all number are English punctuation)

## **តារាងទី១.** បរិមាណអង្ករកម្ពុជាដែលបាននាំចេញប្រចាំខែ ក្នុងឆ្នាំ ២០១២ - ២០១៦, គិតជាតោន

(Table1. Quantity of Cambodian Rice have been Exported by months of 2012-2016, in tones)

| | Month/ Year | 2012 | 2013 | 2014 | 2015 | 2016 | VARIATION |
|---|---|---|---|---|---|---|---|
| 1 | មករា (January) | 9,703 | 25,726 | 21,536 | 35,921 | 44,033 | +22.60% |
| 2 | កុម្ភៈ (February) | 14,417 | 24,089 | 27,037 | 37,676 | 51,912 | +37.80% |
| | **Sub-Total for 2 months** | **24,120** | **49,815** | **48,573** | **73,597** | **95,945** | **+30.40%** |
| 3 | មិនា (March) | 12,310 | 45,413 | 35,757 | 75,867 | | |
| 4 | មេសា (April) | 15,036 | 23,276 | 35,961 | 51,719 | | |
| 5 | ឧសភា ( May) | 13,115 | 28,350 | 27,971 | 41,842 | | |
| 6 | មិថុនា (June) | 13,426 | 29,105 | 29,666 | 40,800 | | |
| 7 | កក្កដា (July) | 20,527 | 31,411 | 26,060 | 28,492 | | |
| 8 | សីហា (August) | 15,530 | 29,358 | 29,871 | 29,819 | | |
| 9 | កញ្ញា (September) | 15,169 | 29,395 | 35,511 | 26,969 | | |
| 10 | តុលា (October) | 16,967 | 28,031 | 35,418 | 39,064 | | |
| 11 | វិច្ឆិកា (November) | 25,189 | 37,855 | 31,137 | 48,748 | | |
| 12 | ធ្នូ (December) | 34,328 | 46,847 | 51,136 | 81,479 | | |
| | **GRAND TOTAL** | **205,717** | **378,856** | **387,061** | **538,396** | | |

## **តារាងទី២.** ប្រភេទអង្ករកម្ពុជាដែលបាននាំចេញក្នុង២ខែដើមឆ្នាំ ២០១៦, គិតជាតោន

(Table 2. Type of Cambodian Rice have been Exported in February 2016, in tones)

| | ប្រភេទអង្ករ | មករា | កុម្ភៈ | សរុប (TOTAL) | |
|---|---|---|---|---|---|
| | **TYPE OF RICE** | **JANUARY** | **FRABRUARY** | **MT** | **%** |
| **I. អង្ករក្រអូប /JASMINE/ FRAGRANT RICE:** | | | | | |
| 1 | ចម្រុះ (F.SENKRAOB, NEANG SAUY....) | 5,888 | 7,024 | 12,912 | 13.50 |
| 2 | នាងម្លិស (F. NEANG MALIS) | 1,787 | 1,207 | 2,994 | 3.10 |
| 3 | សូមាលី .( F. SOMALY) | 214 | 216 | 430 | 0.40 |
| 4 | ផ្ការំដួល /ផ្កាម្លិស/ (J.PHKA RUMDUOL/ MALIS) | 14,672 | 13,629 | 28,301 | 29.40 |
| 5 | សរីរាង្គ (J.ORGANIC) | 414 | 180 | 594 | 0.60 |
| 6 | ភ្លី . (F. PEARL) | 48 | 920 | 968 | 1.00 |
| | SUB-TOTAL | 23,023 | 23,176 | 46,199 | 48.10 |
| **II. អង្ករសគ្រាប់វែង /WHITE LONG GRAIN RICE:** | | | | | |
| 1 | ចម្រុះគ្រាប់វែង (LONG GRAIN) | 18,310 | 24,878 | 43,188 | 45.00 |
| 2 | ប្រណិតគ្រាប់វែង (PREMIUM LONG GRAIN) | 445 | 488 | 933 | 1.00 |
| | SUB-TOTAL | 18,755 | **25,366** | 44,121 | 46.00 |
| **III. អង្ករចំហុយគ្រាប់វែង/ LONG GRAIN PABOILLED:** | | | | | |
| 1 | ចំហុយគ្រាប់វែង (LONG GRAIN PABOILLED) | 2,255 | 3,370 | 5,625 | 5.90 |
| | SUB-TOTAL | 2,255 | **3,370** | 5,625 | 5.90 |
| | **GRAND TOTAL** | **44,033** | **51,912** | **95,945** | **100.00** |